**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

តុលាការខេត្តកណ្តាល
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៨២ អ.ក ចុះថ្ងៃទី ២៤
ខែ តុលា ឆ្នាំ ១៩៩៥
សាលក្រម
លេខ ៥៤ ព ចុះថ្ងៃទី ១៩
ខែ ធ្នូ ឆ្នាំ ១៩៩៥

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកណ្តាល

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដោយមាន :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី

សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
ដោយពុំមានភាគីណាមួយបានប្តឹងតវ៉ាតាមការកំណត់របស់ច្បាប់ ។
កណ្តាល, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
ក្រឡាបញ្ជី
[redacted]

**ដើម្បីជំនុំជំរះ :**

ឈ្មោះ **ម សរ** ហៅ ម ភេទប្រុស អាយុ ៣២ឆ្នាំ "យុំខ្លួន" កើតនៅភូមិស្ទឹង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល របររកស៊ី នគរបាលចរាចរផ្លូវទឹកក្រសួងមហាផ្ទៃ គិរិតវប្បធម៌ថ្នាក់ទី៧ថ្មី សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រពន្ធឈ្មោះ **ឌ សរអ** មានកូន ០២ នាក់ ឪពុកឈ្មោះ **ឆ ម** (ស) ម្តាយឈ្មោះ **ម អ** (រ) ទោសពីមុន *គ្មាន* ។

ត្រូវចោទពីបទ : **បង្ករបួសស្នាមដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តុលាការសំរេចទទួលស្គាល់លោក **សេង ពិសិដ្ឋ** តាមដីកាលេខ ៣៣៣ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥ ជាអ្នកការពារជនជាប់ចោទឈ្មោះ **ម សរ** ។

យោងតាមកំណត់ហេតុល្មើសច្បាប់ជាក់ស្តែង ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ និង យោងតាមដីកាសន្និដ្ឋានស្ថាពរលេខ ២៧១ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ព្រះរាជអាជ្ញា ។

បានឃើញ
ប្រធានតុលាការខេត្តកណ្តាល
[redacted]

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ ម៉ោងប្រហែល ៦:០០នាទី ឈ្មោះ **ម សរ** ក្រោយពីហូបចុករួចត្រូវ



Scanned with CamScanner

មិត្តភក្តិជាកងជីវពលឈ្មោះ រ បរ និង ឈ្មោះ ទ ស ដែលដើរធ្វើការជាមួយ ហើយឈ្មោះ ម សរ ក៏ឡើងលើផ្ទះយកកាំភ្លើង AK បត់មួយដើមស្ពាយដើរធ្វើការជាមួយអ្នកទាំងពីរ លុះដល់ម៉ោងប្រហែល ៨:០០យប់កំពុងដើរធ្វើការក៏បានជួបនគរបាលស្រុកឈ្មោះ ហ សរ ពេលឈ្មោះ ហ សរ ក៏បានភ្លង់ឈ្មោះ រ បរ បានបាញ់ឡើងលើ ២. ៣គ្រាប់ ហើយក៏បានចូលដកកាំភ្លើងខ្លីពីឈ្មោះ ហ សរ ហើយពេលនោះដែរឈ្មោះ ម សរ ក៏បានបាញ់ភ្លុចដី ២. ៣គ្រាប់ដែរ បណ្តាលអោយត្រូវកែងជើងឈ្មោះ ហ សរ ហើយចាប់នាំឈ្មោះ ហ សរ មកមន្ទីរឃុំមិនទាន់មកដល់មន្ទីរឃុំផង ឈ្មោះ ម សរ បានបាញ់មួយគ្រាប់ទៀតចុះទៅដី លុះមកដល់មន្ទីរឃុំ ម សរ ក៏ប្រគល់ ហ សរ អោយទៅមន្ទីរឃុំ ម សរ ក៏ជិះម៉ូតូជាមួយបងមកផ្ទះដល់ម៉ោង ១២:០០នាទីយប់ បង ម សរ មកហៅ ម សរ ទៅឃុំវិញ ពេលនោះភ្នាក់ងារមានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-បានឃើញកំណត់ហេតុល្មើសច្បាប់ជាក់ស្តែង ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ ។

-បានឃើញកំណត់ហេតុ ពិនិត្យ និង វិភាគកន្លែងកើតហេតុ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ ។

-បានឃើញរបាយការណ៍បំភ្លឺ ស្តីពីការព្យាបាលជម្ងឺរបស់សុខាភិបាលស្រុកកៀនស្វាយលេខ ២០៩ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥ ។

-បានឃើញកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ ។

-បានឃើញកំណត់ហេតុទទួលស្គាល់វត្ថុតាងពីជនល្មើស ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកកៀនស្វាយ ។

-បានឃើញលិខិតទទួលប្រាក់ព្យាបាលជម្ងឺ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥ រវាងជនរងគ្រោះ និងតំណាងជនល្មើស ។

-បានឃើញលិខិតសំណូមពររបស់ជនរងគ្រោះឈ្មោះ ហ សរ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។

-បានឃើញដីកាជូនរឿងជំនុំជំរះលេខ ២០២ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមលេខ ២៣៥ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ប្រធានតុលាការ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ ម សរ ហៅ ម បានឆ្លើយសារភាពថា ខ្លួនពិតជាបានបង្កអោយឈ្មោះ ហ សរ មានរបួសស្នាមប្រាកដមែន ដោយនៅល្ងាចថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ ខ្លួនបានហូបស្រាជាមួយក្រុមគ្រួសារនៅផ្ទះខ្លួនបានឃើញឈ្មោះ ស និង ឈ្មោះ បរ ចុះធ្វើការតាមមូលដ្ឋាន ដោយមានកាំភ្លើង AKមួយដើមម្នាក់ផង ខ្លួនក៏ហៅអោយហូបស្រាបន្តិចបន្តួច រួចក៏ចេញមកធ្វើការនៅក្នុងភូមិម្តាយខ្លួន។ ក៏សុំគេទៅធ្វើការជាមួយខ្លួនក៏យកកាំភ្លើង AK ទៅជាមួយជីវពលឃុំទៅ ។ លុះដើរដល់ផ្លូវកែងកាច់បណ្តោយភូមិឈ្មោះ ស ប្រាប់ខ្លួនថា មានគេភ្លង់ ហើយស្រាប់ តែឮសូរកាំភ្លើងផ្ទុះមួយគ្រាប់ពុំដឹងបាញ់ រួចឃើញឈ្មោះ ហ សរ កាន់កាំភ្លើងខ្លីភ្លង់ បរ ពេលនោះឈ្មោះ ស ប្រាប់ថា ម្នាក់នេះភ្លង់ខ្ញុំ ខ្លួនក៏បាញ់កាំភ្លើងភ្លុចដីជាច្រើនគ្រាប់ក្បែរជើង ហ សរ តែខ្លួនពុំដឹងថា ត្រូវជើងគេទេ ហើយ បរ ក៏ដកអាវុធពីដៃរបស់ ហ សរ រួចខ្លួនក៏ដេកខ្លួន ហ សរ ហើយអោយគាត់ដោះអាវខោចេញ និង



Scanned with CamScanner

អោយគាត់ទៅឃុំ តែគាត់មិនចង់ទៅ និង ដោះខោអាវ ខ្លួនក៏បាញ់ឡើងលើមួយគ្រាប់ ហើយច្រានគាត់អោយទៅ និង យកកាំភ្លើងក្រវាត់លើខ្នងគាត់ ៣. ៤កាំភ្លើង លុះដើរទៅមុខបានបន្តិចគាត់មិនចង់ដើរទៅទៀត ខ្លួនក៏បាញ់ភ្លុចដីមួយគ្រាប់ និង យកកាំភ្លើងវាយលើខ្នងគាត់មួយកាំភ្លើងទៀត តែមិនមែនវាយពីស្ទ័យទេ គឺវាយនឹងចុងកាំភ្លើង រួចមកក៏យកទៅអោយប៉ុស្តិ៍នគរបាលឃុំ ហើយខ្លួនក៏ទៅផ្ទះ លុះក្រោយបន្តិចគេឃាត់ និង ចាប់ខ្លួនតែម្តង ។ ពេលបាញ់នោះខ្លួនពុំដឹងថា ត្រូវជើងគាត់ទេ លុះគេនាំខ្លួនទៅពេទ្យ ទើបឃើញគាត់របួសជើង ។ ពីមុនមកខ្លួនតែងតែចូលរួមចុះធ្វើការការពារសន្តិសុខក្នុងភូមិជាមួយជីវពលឃុំជាញឹកញាប់ ។ ខ្លួនគ្មានគំនិតបាញ់ជើងគាត់អោយរបួសទេ គឺខ្លួនគ្រាន់ តែបាញ់ភ្លុចដីក្បែរជើងគាត់តែប៉ុណ្ណោះ ដើម្បីគំរាមគាត់ និង ដកយកអាវុធពីគាត់ប៉ុណ្ណោះ ។

-ឈ្មោះ **ឃា សរ** ជាជនរងគ្រោះបានឆ្លើយថា យប់ថ្ងៃកើតហេតុនោះ ខ្លួនបានយកម៉ូតូទៅផ្ញើទុកនៅផ្ទះគេ រួចខ្លួនក៏ដើរមកផ្ទះ ដោយកាន់កាំភ្លើងខ្លីនៅដៃ លុះដើរមកបានបន្តិចស្រាប់តែមានគេបញ្ចាំងពិលដាក់មុខខ្លួន ហើយគេសួរថា អ្នកណា ? ខ្លួនថាខ្ញុំ បើចង់ដឹងចុចពិលដាក់មុខស្គាល់ហើយ ។ ពេលនោះឈ្មោះ **ល ថ** ស្គាល់ខ្លួនច្បាស់ក៏នាំគ្នាដើរទៅមុខទៀត លុះដើរដល់មុខផ្ទះខ្លួនគេសួរខ្លួនថា ចេះហូបស្រាទេ ខ្លួនថាមិនចេះទេ ហើយគេសុំផ្ទះខ្លួនផឹកស្រាខ្លួនថា កុំហូបផ្ទះខ្លួនអី ហើយគេសួរខ្លួនថា មានកាំភ្លើងទេ ខ្លួនថាអត់ទេ ។ ពេលនោះឈ្មោះ **ឋរ** ដកយកកាំភ្លើងពីខ្លួន ។ ខ្លួនពុំបានភ្ជង់កាំភ្លើងគេទេ ក្រោយពីគេដកអាវុធពីខ្លួនមក ស្រាប់តែផ្ទុះអាវុធតែម្តង ដោយបាញ់ឡើងលើជាច្រើនគ្រាប់ និង បាញ់ភ្លុចដីជាច្រើនគ្រាប់ដែរ ហើយស្រាប់តែគ្រាប់មួយគ្រាប់ ត្រូវកែងជើងខ្លួនធ្លាយតែមិនប៉ះពាក់ដល់ឆ្អឹងទេ ។ អ្នកបាញ់ត្រូវជើងខ្លួននោះគឺ ឈ្មោះ **ម** ។ ក្រោយពីបាញ់មកគេក៏បង្ខំខ្លួនអោយមកសាលាឃុំ ខ្លួនក៏មកតាម តែតាមផ្លូវឈ្មោះ **ម** បានវាយខ្លួន និង កាំភ្លើងជាច្រើនកាំភ្លើង ប៉ុន្តែវាយសំប៉ាតទេ មិនមែនវាយនឹងស្ទ័យកាំភ្លើងទេ លុះនាំខ្លួនមកដល់សាលាឃុំនគរបាលប៉ុស្តិ៍ក៏យកខ្លួនទៅពេទ្យ ។ ចំពោះឈ្មោះ **ម** បង្កលើខ្លួននេះខ្លួនពុំទាមទារសំណងជម្ងឺចិត្ត និង ការព្យាបាលអ្វីបន្ថែមទៀតទេ ព្រោះខ្លួនកំពុងព្យាបាលគ្រួសារឈ្មោះ **ម** បានជួយចេញប្រាក់ព្យាបាលមកខ្លួនហើយ ។ ខ្លួនពុំបានសំណូមពរអ្វីក្រៅពីសុំអោយតុលាការសំរេចតាមច្បាប់ចុះ ។

-ឈ្មោះ **ខ ស** សាក្សីបំភ្លឺបានឆ្លើយបំភ្លឺថា ខ្លួន និង ឈ្មោះ **ឋរ** ត្រូវមេឃុំបញ្ជាអោយចុះធ្វើការតាមភូមិ ព្រោះមានចោរចូលលួចមាន់,គោ,ជ្រូក,ក្របី ក្នុងភូមិពេលចុះទៅនោះមានកាំភ្លើងម្នាក់មួយដើម ។ ពេលដើរដល់មុខផ្ទះឈ្មោះ **ម ៗ** ហៅអោយ **ឋរ** ចូល រួចអោយហូបស្រា ឯខ្លួនពុំបានហូបស្រាទេ រួចក៏នាំគ្នាធ្វើដំណើរទៅទៀត ហើយខ្លួនក៏បបួលឈ្មោះ **ម** ទៅជាមួយរួចឈ្មោះ **ម** ក៏យកកាំភ្លើង AK របស់គេទៅជាមួយពួកខ្លួន ។ ពេលមកដល់ផ្លូវដាច់ជួបឈ្មោះ **យ** ឈ្មោះ **ម** ក៏សុំត្រី ហើយឈ្មោះ **ម** អោយខ្លួនចាំយក ឯឈ្មោះ **ឋរ** និង ឈ្មោះ **ម** ដើរទៅមុខ ។ ខ្លួនចាប់មិនទាន់បានត្រីផង ស្រាប់តែមានជនម្នាក់មិនស្គាល់មកភ្ជង់កាំភ្លើងខ្លួនៗ សួរថាអ្នកណាជននោះមិនឆ្លើយខ្លួនក៏រត់ទៅរក **ឋរ** និង **ម** ហើយស្រាប់តែអ្នកទាំងពីរ រួចខ្លួនក៏មកវិញ តែពុំឃើញអ្នកដែលភ្ជង់ខ្លួនៗក៏ដើរមករកអ្នកទាំងពីរវិញ ស្រាប់តែឃើញ **ឋរ** ប្រទ្រូសប្រតាសគ្នាជាមួយអ្នករងគ្រោះនេះ ខ្លួនក៏ថាគាត់ហើយភ្ជង់អញ ។ តែពេលដែលជនរងគ្រោះ និង ឈ្មោះ **ឋរ** កំពុងប្រទ្រូសប្រតាសគ្នានោះ ឈ្មោះ **ម សរ** ក៏បាញ់កាំភ្លើងភ្លុចដី ៣.៤គ្រាប់ ទើបដកកាំភ្លើង ពីជនរងគ្រោះបាន ។ ឯខ្លួនក៏បានបាញ់ឡើងលើមួយគ្រាប់ដែរ លុះឈ្មោះ **ម សរ** ឈប់បាញ់ជនរងគ្រោះប្រាប់ខ្លួនថា ត្រូវជើងហើយខ្លួនក៏បបួលទៅសាលាឃុំ ហើយ **ម សរ** ក៏យកកាំភ្លើងគាស់អោយជនរងគ្រោះអោយទៅ លុះដើរដល់ផ្ទះម៉ែធមិរបស់គាត់ៗមិនចង់ទៅឈ្មោះ **ម សរ** ក៏បាញ់ភ្លុចដីមួយគ្រាប់ទៀត ហើយវាស់កាំភ្លើងនាំគាត់រហូតដល់សាលាឃុំ ហើយកាំភ្លើងដែលដកពីជនរងគ្រោះក៏ប្រគល់អោយឃុំនៅពេលនោះដែរ ។ កន្លងមកឈ្មោះ **ម សរ** ធ្លាប់ជួយសហការ ការងារជាមួយជីវពលឃុំ ។



Scanned with CamScanner

-ឈ្មោះ រ ឋរ សាក្សីបំភ្លឺបានឆ្លើយថា នៅថ្ងៃកើតហេតុនោះខ្លួនត្រូវមេឃុំបញ្ជាអោយខ្លួនចុះធ្វើការនៅតាម ភូមិជាមួយឈ្មោះ ខ ស ដោយមានកាន់កាំភ្លើង AKមួយដើមម្នាក់ ពេលដើរមកដល់ផ្ទះ ម សរ ៗ បានហៅខ្លួនចូលអង្គុយលេង ហើយអោយស្រាផឹក តែ ស មិនបានហូបទេ មួយសន្ទុះក្រោយមកឈ្មោះ ស បានហៅខ្លួនទៅធ្វើការទៀត ខ្លួនក៏បបួលឈ្មោះ ម សរ ៗ ក៏យកកាំភ្លើង AK របស់គេទៅជាមួយ ។ លុះដើរបានបន្តិចក៏ជួបឈ្មោះ យ ឈ្មោះ ម សរ ក៏សុំត្រីឈ្មោះ យ ហើយអោយឈ្មោះ ស ចាំយកត្រី ឯខ្លួន និង ម សរ ក៏ដើរទៅមុខទៀត បន្ទាប់មកឈ្មោះ ស រត់ទៅតាមក្រោយហើយប្រាប់ថា មានគេភ្ជង់កាំភ្លើងវា រួចឈ្មោះ ស ក៏បកមកក្រោយវិញ ខ្លួន និង ឈ្មោះ ម សរ ទៅតិចៗទៅមុខទៀត ទន្ទឹមនេះដែរស្រាប់តែជនរងគ្រោះភ្ជង់ខ្លួនៗចាប់កាំភ្លើងជាប់ជននោះសួរថា ពីណាអោយខ្លួនមកមេ អោយចុះមក ពេលនោះឈ្មោះ សរ ហៅ ម ថា កាំភ្លើងក្នុងគេនៅឯណា រួចក៏បាញ់ភ្ជុះដី ៤.៥គ្រាប់ ហើយនាំទៅសាលាឃុំ ពេលនោះជនរងគ្រោះថា ត្រូវដឹងហើយខ្លួនថាទៅឃុំដោះស្រាយគ្នា តែគាត់មិនទៅឈ្មោះ ម សរ ក៏យកកាំភ្លើងរុញអោយដើរ ។ លុះដើរបានបន្តិចឈ្មោះ សរ អោយជនរងគ្រោះស្រាតខោអាវរួចបាញ់ ០១គ្រាប់ភ្ជុះដីទៀត ហើយនាំទៅសាលាឃុំ ចំណែកកាំភ្លើងខ្លីដែលដកពីជនរងគ្រោះ ប្រគល់ឱ្យឃុំទាំងយប់នោះ ។ ពេលកើតហេតុនោះ ខ្លួនបានបាញ់មួយគ្រាប់ដែរ តែបាញ់ឡើងលើ ។

-ឈ្មោះ ម សរ សាក្សីបំភ្លឺបានឆ្លើយថា ពេលកើតហេតុខ្លួនពុំបានដឹងទេ លុះគេនាំជនរងគ្រោះមកឃុំ ឈ្មោះ ស មកប្រាប់ថា មានជនមិនស្គាល់ឈ្មោះជានគរបាលស្រុក ដោយចាំយូរពេកខ្លួនក៏ដើរទៅមើលដល់ពេទ្យ ឃើញជនរងគ្រោះរបួសជើង ហើយទើបស្គាល់ថា ជាកំលាំងរបស់ស្រុក ។ ចំពោះកាំភ្លើងខ្លីកាបុបឈ្មោះ ម សរ យកមកប្រគល់អោយខ្លួន ខ្លួនពុំដឹងថា នគរបាលរូបនេះចុះមកមូលដ្ឋានខ្លួនទេ ក្រែងគេប្រាប់មេឃុំ ឬ នគរបាលប៉ុស្តិ៍ក៏មិនដឹង ។ ចំណែក ឈ្មោះ ស និង ឈ្មោះ ឋរ ខ្លួនជាអ្នកបញ្ជាអោយចុះ ។

-តាមអំណានចម្លើយឈ្មោះ ឈ អ ជាសាក្សីបំភ្លឺថា កាលពីថ្ងៃមិនចាំខែតុលា ឆ្នាំ ១៩៩៥ វេលាម៉ោងប្រហែល ១១:00នាទីថ្ងៃត្រង់ បង រ បានហៅខ្ញុំអោយចូលហូបស្រាជាមួយនឹងគាត់ នឹងផ្ទះបង ម មានគ្នា បង ម បង រ បង ស បង ព .ខ និង រូបខ្ញុំហូបរួចហើយ ក៏ចេញដំណើរទៅផ្ទះឈ្មោះ ល ៩ ក្នុងគោលបំណងទៅហូបស្រាទៀត ពេលទៅដល់ផ្ទះពូ យ នៅភូមិព្រៃកតាកែវបានជួបឈ្មោះតា រ ហៅ ត ហើយខ្ញុំក៏ធ្វើដំណើរទៅផ្ទះរបស់ខ្ញុំតែម្តង ខ្ញុំដើរពីរនាក់បង រ ដល់ព្រែកបាក់ខ្ញុំដើរជាមួយបង ស ដល់ព្រែកបាក់បង ម សួរបង ត ថា បងឯងមានកាំភ្លើង ឬ អត់ បង ត ឆ្លើយថាគ្មានទេ បង ត កាន់កាំភ្លើងនៅនឹងដៃ រួចហើយបង ត ភ្ជង់គ្នា ពេលនោះបង ត ភ្ជង់មុន គឺភ្ជង់អ្នកដើរទាំងអស់គ្នា ស្រាប់តែឮស្នូរកាំភ្លើងខ្ញុំក៏រត់ទៅផ្ទះតែម្តងទៅ ឮស្នូរបាញ់នោះមិនដឹងកាំភ្លើងអីទេ ហើយមិនដឹងអ្នកណាបាញ់ទេ ពេលនោះខ្ញុំទៅដល់ផ្ទះយប់ម៉ោង ៧:00នាទីហើយ ខ្ញុំក៏ដេកតែម្តងទៅខ្ញុំអត់បានដឹងអីទៀតទេ ព្រោះខ្ញុំដល់ផ្ទះរបស់ខ្ញុំហើយ ។

-តាមអំណានចម្លើយឈ្មោះ ល ៩ ជាសាក្សីបំភ្លឺថា នៅថ្ងៃមិនចាំ ខែ តុលា ឆ្នាំ ១៩៩៥ ម៉ោង ០៥ល្ងាច ខ្ញុំឡើងពីរកត្រីនៅបឹងបំរុងទៅផ្ទះខ្ញុំ ពេលនោះបង ឋរ ស្រែកហៅខ្ញុំអោយត្រឡប់ក្រោយចូលផ្ទះបង ម សរ ហៅ ម ខ្ញុំបាន ឃើញបង សរ .ឋរ.ឈ អ កំពង់ហូបស្រាក្រោមផ្ទះលើគ្រែ ខ្ញុំបានហូបស្រាបន្តិចដែរ រួចហើយបង ឋរ សួរខ្ញុំថា នៅផ្ទះមានមាន់ទេ ខ្ញុំតបវិញថា មាន់អត់មានទេ មានតែត្រី ។ និយាយរួចចេញដំណើរទៅផ្ទះខ្ញុំទាំងអស់គ្នា រៀបនឹងចេញក៏បានឃើញបង ស មកដល់ ពេលនោះ ខ ស អត់ហូបស្រាទេ ។ បន្ទាប់ពីបានជួបគ្នាទាំងអស់រួចហើយក៏ធ្វើដំណើរចូល ភូមិតាមផ្លូវខាងលិចផ្ទះបង សរ ដើរដល់ផ្ទះបង យ សុំត្រីប្រឡាក់មិនដឹងបាន ឬ អត់ទេ ពេលនោះខ្ញុំបានជួបឈ្មោះ ហ សរ ខ្ញុំក៏ទៅមុខជាមួយគាត់ ពេលទៅដល់មុខផ្ទះភ្លាមៗមិនទាន់ចូលផ្ទះគាត់ទេ ខ្ញុំក៏



Scanned with CamScanner

លាគាត់ទៅផ្ទះខ្ញុំទៅ ពេលដែលខ្ញុំដើរជាមួយបង សរ នេះខ្ញុំឃើញបង សរ កាន់កាំភ្លើងខ្លីនៅដៃរបស់គាត់ តែខ្ញុំមិនស្គាល់ម៉ាកកាំភ្លើងនោះទេ ពេលដែលខ្ញុំលាបង សរ ហើយខ្ញុំបានដើរទៅផ្ទះ ខ្ញុំចូលផ្ទះបានបន្តិចស្រាប់តែឮស្នូរផ្ទុះអាវុធជាច្រើនគ្រាប់ តែខ្ញុំមិនដឹងជាមានកើតហេតុអ្វីទេ បានមួយស្របក់ខ្ញុំបានឮស្រែកឡូឡាដើរកាត់មុខផ្ទះខ្ញុំដោយបណ្តើរឈ្មោះ សរ អ្នកដែលបណ្តើរនោះគឺ សរ ,ស ,មរ ពេលនោះខ្ញុំចេញទៅមើលបង សរ បានសុំដៃកកេះខ្ញុំបំភ្លឺមើលជើងរបស់គាត់ ខ្ញុំឃើញជើងរបស់គាត់ហូរឈាមតិចៗតាមមុខរបួស ។ បន្ទាប់ពីបំភ្លឺមើលជើងហើយអ្នកទាំងបួននាក់នោះ នាំគ្នាបណ្តើរទៅតាមផ្លូវលំឆ្ពោះទៅទិសខាងកើតទៅខ្ញុំមិនបានដឹងអ្វីទៀតទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ ម សរ ពីបទ : បង្ករបួសស្នាមដោយចេតនា កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ ហើយសំរេចតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៧១ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់តំណាងអយ្យការទុកជាបានការពេញលេញ និង សំណូមពរផ្តន្ទាទោសជនជាប់ចោទតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-អ្នកការពារសិទ្ធិជនជាប់ចោទបានលើកឡើងក្នុងសេចក្តីសន្និដ្ឋានការពារថា មិនជំទាស់ ឬ បដិសេធការចោទប្រកាន់របស់តំណាងអយ្យការទេ ប៉ុន្តែសូមសំណូមពរមេត្តាពិនិត្យកត្តាខ្លះៗ ដែលនាំអោយរឿងកើតឡើង និងសូមមេត្តាសំរាលអោយរួចទោស ដោយយប់នោះពួកគេត្រូវជនរងគ្រោះគំរាមធ្វើអោយជនជាប់ចោទបាញ់សំឡុតដើម្បីដកអាវុធ ប៉ុន្តែគ្មានបំណងធ្វើអោយរបួសទេ ។

-ជនរងគ្រោះកាន់កាំភ្លើងក្នុងមិត្តភក្តិគេ

-ជនជាប់ចោទធ្លាប់រួមសហការជាមួយមូលដ្ឋានការពារសន្តិសុខ ថ្វីត្បិតតែគ្មានបញ្ហាពីមេក៏ដោយ

-ប្រពន្ធជនល្មើសមានផ្ទៃពោះជិតគ្រប់ខែមានកូនតូច ០២នាក់ និង ម្តាយចាស់ជរាសង្ឃឹមលើគេម្នាក់នេះ

-ជនរងគ្រោះបានទទួលប្រាក់សំណងជម្ងឺចិត្ត និង ការព្យាបាលរួចហើយ

-ជនជាប់ចោទឈ្មោះ ម សរ បានធ្វើសំណូមពរជាចុងក្រោយ សូមអោយតុលាការមេត្តាអធ្យាស្រ័យនូវទោសកំហុសរបស់ខ្លួន ។ ដើម្បីខ្លួនបានទៅរកស៊ីចិញ្ចឹមកូនប្រពន្ធ ដែលជិតគ្រប់ខែ និង ម្តាយចាស់ជរាផង ។

-បានស្តាប់ចម្លើយជនជាប់ចោទ

-បានស្តាប់ចម្លើយជនរងគ្រោះ

-បានស្តាប់ចម្លើយសាក្សីបំភ្លឺ

-បានពិនិត្យភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់អ្នកការពារជនជាប់ចោទ

-បានស្តាប់ចម្លើយជនជាប់ចោទជាចុងក្រោយ

## <u>តុលាការខេត្តកណ្តាល</u>

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>យល់ឃើញថា</u>

-នៅល្ងាចថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នៅចំណុចភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ពិតជាមានអំពើល្មើសច្បាប់មួយ ដែលបង្កដោយឈ្មោះ ម សរ ទៅលើជនរងគ្រោះឈ្មោះ មា



Scanned with CamScanner

**សរ** ពិតប្រាកដមែន ។

-នៅល្ងាចថ្ងៃកើតហេតុនោះឈ្មោះ **ម សរ** ពិតជាបាញ់កាំភ្លើងភ្ញុចដីបណ្តាលអោយរបួសជើង និង វាយលើឈ្មោះ **ហ សរ** ជនរងគ្រោះពិតប្រាកដមែន ។

-ច្បាប់របស់រដ្ឋកម្ពុជាតែងការពារទប់ស្កាត់រាល់អំពើបំពារបំពានលើរូបកាយ អាយុជីវិត ចរិយាសម្បត្តិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលបានរស់នៅក្នុងប្រទេសកម្ពុជា តែបើជនណាបានទៅបំពារបំពាន ទោះបីចេតនាក្តី អចេតនាក្តី ជននោះត្រូវទទួលទោសតាមអំពើដែលខ្លួនបានប្រព្រឹត្តជាក់ស្តែងដូចជាឈ្មោះ **ម សរ** នេះជាភស្តុតាងស្រាប់ ។

-អំពើរបស់ឈ្មោះ **ម សរ** ដែលបានបាញ់កាំភ្លើង និង វាយទៅលើជនរងគ្រោះបណ្តាលអោយជនរងគ្រោះ មានរបួសស្នាមយ៉ាងនេះ ជាអំពើមួយមិនអាចអត់អោនអោយបានឡើយ ។

-ទោះបីជនរងគ្រោះ ត្រូវរបួសកែងជើងមិនបណ្តាលអោយពិការយូរខែក៏ដោយ ក៏ជនជាប់ចោទឈ្មោះ **ម សរ** នេះ ត្រូវតែទទួលខុសត្រូវនូវអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តដែរ ។

-បើពិនិត្យលើកត្តាអត្តនោម័តរបស់ជនជាប់ចោទរូបនេះឃើញថា ត្រូវតែទទួលទោសតាមច្បាប់យ៉ាងតឹងរឹងបំផុត ប៉ុន្តែបើពិនិត្យលើកត្តាសត្យានុម័តវិញ ឃើញថាអំពើនេះក៏បណ្តាលមកពីជនរងគ្រោះដែរ បើកុំតែជនរងគ្រោះមានកាំភ្លើង ហើយកាន់នៅដៃម្ញេះសមឈ្មោះ **ម សរ** ពុំបានបាញ់ភ្ញុចដីគំរាមបណ្តាលអោយមានរបួសស្នាមដូច្នេះដែរ ។ ជនជាប់ចោទរូបនេះពុំដែលមានទំនាស់ ឬ បានឈ្លោះប្រកែកអ្វីជាមួយជនរងគ្រោះ ពីពេលមុនក៏ដូចជាពេលកើតហេតុនេះទេ ។

-ជនជាប់ចោទបានបាញ់នេះ ក្នុងបំណងគ្រាន់តែអោយជនរងគ្រោះឈ្មោះ **ហ សរ** ភ័យខ្លាច និង ប្រគល់អាវុធខ្លីអោយមកពួកខ្លួនតែប៉ុណ្ណោះ ។

-ជនជាប់ចោទទឹកស្អានថា ជនរងគ្រោះជាប្រភេទមនុស្សមិនល្អ ដោយក្រោយពីប្រព្រឹត្តគេបាននាំជនរងគ្រោះ មកប្រគល់អោយរដ្ឋអំណាចឃុំដើម្បីស្រាវជ្រាវបន្ត ។

-ជនជាប់ចោទសារភាពដោយស្មោះត្រង់មិនរត់គេចខ្លួន មានជីវភាពក្រីក្រ និង មានការលំបាកយ៉ាងខ្លាំងក្នុងគ្រួសារ ដោយប្រពន្ធមានផ្ទៃពោះជិតគ្រប់ខែ កូនតូចៗ និង ម្តាយចាស់ជរាក្នុងបន្ទុក ។

-មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ **ម សរ** ពីបទ : បង្ករបួសស្នាម កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ នៅភូមិព្រៃកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

-អំពើរបស់ជនជាប់ចោទរូបនេះ ត្រូវតែផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនរងគ្រោះបានទទួលសំណងជម្ងឺចិត្ត និង ការព្យាបាលរួចរាល់ហើយ បញ្ហានេះតុលាការពុំលើកយកមកពិចារណាឡើយ ។

-អ្នកការពារសិទ្ធិជនជាប់ចោទសំណូមពរអោយតុលាការដាក់ទណ្ឌកម្ម ដោយយកមាត្រា ៦០,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីសំរាលទណ្ឌកម្ម បញ្ហានេះតុលាការបានពិចារណារួចហើយ ។

-តាមបញ្ញត្តិ ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះសំរេច

១-ផ្តន្ទាទោស : ឈ្មោះ **ម សរ** ហៅ **ម** ភេទប្រុស អាយុ ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ខែ ប៉ុន្តែទោសនេះត្រូវដាក់ពន្ធនាគារចំនួន ០២ខែ គិតពីថ្ងៃចាប់ខ្លួនពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ ឯទោស



Scanned with CamScanner

សល់ពីនេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង ០៥ឆ្នាំគិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។ បទល្មើស : **បង្ករបួសស្នាមដោយចេតនា** កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ នៅភូមិព្រៃកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោស តាមមាត្រា ៤១.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-វត្ថុតាងមានកាំភ្លើងAKស្វ័យបត់ ១ដើម លេខ ៥១៩៩ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែគិតពីថ្ងៃប្រកាសសាលក្រម ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីសំរេចនេះព្រះករុណា ព្រះចៅក្រុងកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធត្រូវជួយអនុវត្តសាលក្រមអោយបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

**ប្រធានតុលាការ**

[redacted]

*កណ្តាល, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦*

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner